ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

**តុលាការកំពូល**

សភាព្រហ្មទណ្ឌ

សំណុំរឿងព្រហ្មទណ្ឌ

លេខ ២៣៥

ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០២១

**សាលដីកា**

លេខ ៤៣៩ "V"

ចុះថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០២១

[redacted]

# សាលដីកា

## តាងនាមប្រជារាស្ត្រខ្មែរ

## តុលាការកំពូល

បានបើកសវនាការជាសាធារណៈ នៅថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០២១

ដោយមានសមាសភាពអង្គជំនុំជម្រះ ដូចខាងក្រោម៖

១-ឯកឧត្តម [redacted] ជាប្រធាន

២-ឯកឧត្តម [redacted] ជាចៅក្រម

៣-ឯកឧត្តម [redacted] ជាចៅក្រម

៤-ឯកឧត្តម [redacted] ជាចៅក្រម

៥-ឯកឧត្តម [redacted] ជាចៅក្រម

### ក្រឡាបញ្ជីសវនាការ

លោកស្រី [redacted]

### តំណាងមហាអយ្យការ

ឯកឧត្តម [redacted] ឋានៈជាព្រះរាជអាជ្ញា

### ដើម្បីជំនុំជម្រះ

លើបណ្តឹងសាទុក្ខលេខ ៣៤ ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០២១ របស់លោក [redacted]ប៊ុរិន ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted]សាវេត ក្នុងការប្តឹងសាទុក្ខចំពោះសាលដីកាព្រហ្មទណ្ឌលេខ ៩៤ ព្រទ.ក្រIII (ទ.ណ) ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០២១ របស់សភាព្រហ្មទណ្ឌនៃសាលាឧទ្ធរណ៍ត្បូងឃ្មុំ ដែលមាន៖

**-ជនជាប់ចោទ (អ្នកប្តឹងសាទុក្ខ)**

១-ឈ្មោះ[redacted] សាវេត ភេទស្រី អាយុ ៤៥ឆ្នាំ ជនជាតិខ្មែរ ទីកន្លែងកំណើតនៅភូមិត្រាមសរ ឃុំស្តៅ ស្រុកសង្គមថ្មី ខេត្តព្រះវិហារ មានទីលំនៅមុនពេលឃុំខ្លួននៅភូមិតាប[redacted]ៅ ស្រុកសង្គមថ្មី ខេត្តព្រះវិហារ ។ ឪពុកឈ្មោះ[redacted]"ស" ម្តាយឈ្មោះ [redacted] "ស" ប្តីឈ្មោះ [redacted]លុច មានកូន ០១នាក់ ។

ឃុំខ្លួនតាមដីកាបង្គាប់ឱ្យឃុំខ្លួនលេខ ៩០៨ត.ព្រ ចុះថ្ងៃទី១២ ខែមីនា ឆ្នាំ២០២០។

២-ឈ្មោះ [redacted]លុច ភេទប្រុស កើតឆ្នាំ១៩៧៥ ជនជាតិខ្មែរ។ (គេចខ្លួន)



Scanned with CamScanner

ជាប់ចោទពីបទ កាប់គាស់ រុករានដីព្រៃ ឆ្ការ ដុត និងឈូសឆាយដីព្រៃ ដើម្បីធ្វើជាកម្មសិទ្ធិ ប្រព្រឹត្ត[redacted]ស្រុកសង្គមថ្មី ខេត្តព្រះវិហារ កាលពីថ្ងៃទី១២ ខែមីនា ឆ្នាំ២០២០ បទល្មើសព្រហ្មទណ្ឌដែលមានចែងនិងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៦២ កថាខណ្ឌទី១ នៃច្បាប់ស្តីពីតំបន់ការពារធម្មជាតិ ។

-មានលោក [redacted]ស៊ីវិន និងលោក [redacted] បូរ៉ា ជាមេធាវីការពារសិទ្ធិ

**អំពីអង្គហេតុ**

កាលពីថ្ងៃទី១២ ខែមីនា ឆ្នាំ២០២០ ឈ្មោះ[redacted] សាវេត និងឈ្មោះ[redacted]លុច បានប្រព្រឹត្តបទល្មើសកាប់ទន្ទ្រានយកដីព្រៃ និងបរបាញ់សត្វព្រៃដោយខុសច្បាប់ក្នុងតំបន់ការពារ ហើយមន្ត្រីសមត្ថកិច្ចបានធ្វើការណែនាំ និងអប់រំជាច្រើនលើកច្រើនសាររួចមកហើយ តែជនខាងលើនេះនៅតែប្រព្រឹត្តដដែល។

-បានឃើញ សាលក្រមព្រហ្មទណ្ឌលេខ ១២៣ “ខ” ចុះថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០២០ របស់សាលាដំបូងខេត្តព្រះវិហារ ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ៖

១./ផ្តន្ទាទោសជនជាប់ចោទឈ្មោះ [redacted] សាវេត ភេទស្រី អាយុ៤៤ឆ្នាំ (សាវតាជាតិដូចមានខាងលើ) ដាក់ពន្ធនាគារកំណត់ ៥ (ប្រាំ)ឆ្នាំ ពីបទ កាប់គាស់ រុករានដីព្រៃ ឆ្ការ ដុត និងឈូសឆាយដីព្រៃ ដើម្បីធ្វើជាកម្មសិទ្ធិ ប្រព្រឹត្ត[redacted] ស្រុកសង្គមថ្មី ខេត្តព្រះវិហារ កាលពីថ្ងៃទី១២ ខែមីនា ឆ្នាំ២០២០ តាមមាត្រា៦២ កថាខណ្ឌ១ នៃច្បាប់ស្តីពីតំបន់ការពារធម្មជាតិ។

-ផ្តន្ទាទោសជនជាប់ចោទឈ្មោះ [redacted] លុច ភេទប្រុស កើតឆ្នាំ១៩៧៥ ជាតិខ្មែរ (សាវតាជាតិដូចមានខាងលើ) ដាក់ពន្ធនាគារកំណត់ ៦ (ប្រាំមួយ)ឆ្នាំ ពីបទ កាប់គាស់ រុករានដីព្រៃ ឆ្កា ដុត និងឈូសឆាយដីព្រៃ ដើម្បីធ្វើជាកម្មសិទ្ធិ ប្រព្រឹត្ត[redacted] ស្រុកសង្គមថ្មី ខេត្តព្រះវិហារ កាលពីថ្ងៃទី១២ ខែមីនា ឆ្នាំ២០២០ តាមមាត្រា ៦២ កថាខណ្ឌ១ នៃច្បាប់ស្តីពីតំបន់ ការពារធម្មជាតិ។

២./វត្ថុចាប់យករួមមាន៖ គោយន្តកន្ត្រៃគ្មានរ៉ឺម៉កចំនួន០១ គ្រឿង តាមកំណត់ហេតុទទួលវត្ថុតាងលេខ២៤/២០២០ របស់លេខាធិការដ្ឋានរដ្ឋបាលសាលាដំបូងខេត្តព្រះវិហារ ចុះថ្ងៃទី១២ ខែមីនា ឆ្នាំ២០២០ ត្រូវរឹបអូសជាទ្រព្យសម្បត្តិរដ្ឋ។

សាលក្រមនេះជំនុំជម្រះនៅថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០២០ និងប្រកាសជាសាធារណៈនៅថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០២០ ចំពោះមុខជនជាប់ចោទឈ្មោ[redacted]ាវេត និងកំបាំងមុខជនជាប់ចោទឈ្មោ[redacted]លុច បើភាគីមិនសុខចិត្តនឹងសេចក្តីសម្រេចនេះមានសិទ្ធិ

ប្តឹងទាស់, ប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់។

-បានឃើញ បណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០២០ របស់ជនជាប់ចោទឈ្មោះ ឡុង សាវេត ដែលប្តឹងមិនសុខចិត្តនិងសាលក្រមព្រហ្មទណ្ឌលេខ ១២៣ “ខ” ចុះថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០២០ របស់សាលាដំបូងខេត្តព្រះវិហារ គ្រង់ចំណុចទាំងមូលនៃសេចក្តីសម្រេច។

សាលាឧទ្ធរណ៍ត្បូងឃ្មុំ បានសម្រេចតាមអំណាចសាលដីកាព្រហ្មទណ្ឌលេខ ៩៤ ព្រ.ក្រម (ទ.ណ) ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០២១ ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ៖



Scanned with CamScanner

១-ទទួលពាក្យបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០២០ របស់ជនជាប់ចោទឈ្មោះ[redacted] សាវេត ទុកជាត្រឹមត្រូវតាមច្បាប់ តែបដិសេធចោលដោយទាស់នឹងគតិច្បាប់។

២-តម្កល់សាលក្រមព្រហ្មទណ្ឌលេខ ១២៣ "ខ" ចុះថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០២០ របស់សាលាដំបូងខេត្តព្រះវិហារ ទុកជាបានការដដែល ។

សាលដីកានេះ បានប្រកាសជាសាធារណៈនៅថ្ងៃអង្គារ ១៤កើត ខែជេស្ឋ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥ ត្រូវនឹងថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០២១ ចំពោះមុខជនជាប់ចោទឈ្មោះ[redacted]សាវេត ។

ទុកសិទ្ធប្តឹងសាទុក្ខតាមកំណត់ច្បាប់ ។

-បានឃើញ បណ្តឹងសាទុក្ខលេខ ៣៤ ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០២១ របស់លោក[redacted]ស៊ីវិន ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] សាវេត ដែលប្តឹងមិនសុខចិត្តនឹងសាលដីកាព្រហ្មទណ្ឌសាលាឧទ្ធរណ៍លេខ ៩៤ ព្រទ.ក្រIII (ទ.ណ) ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០២១ ត្រង់ចំណុចនៃសេចក្តីសម្រេចទាំងមូល។

## នាពេលសវនាការ

-ចៅក្រមបានអានរបាយការណ៍។

-តំណាងមហាអយ្យការអមតុលាការកំពូល ធ្វើសេចក្តីសន្និដ្ឋានថា៖ ជនជាប់ចោទឈ្មោះ[redacted] សាវេត បានប្តឹងសាទុក្ខ តាមបណ្តឹងលេខ៣៤ ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០២១ ត្រង់ចំណុចទាំងមូលនៃសាលដីកាព្រហ្មទណ្ឌលេខ ៩៤ ព្រទ.ក្រIII (ទ.ណ) ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០២១ របស់សភាព្រហ្មទណ្ឌសាលាឧទ្ធរណ៍ត្បូងឃ្មុំ។ បណ្តឹងសាទុក្ខរបស់ជនជាប់ចោទឈ្មោះ [redacted] សាវេត ធ្វើឡើងផ្ទុយនឹងខ្លឹមសារបញ្ញត្តិមាត្រា ៤២០ កថាខណ្ឌទី១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ពោលគឺ ផុតរយៈពេលកំណត់តាមច្បាប់។ ដូចនេះគប្បីក្រុមប្រឹក្សាជំនុំជម្រះពិចារណា បដិសេធចោលបណ្តឹងនេះជាអសាបង់។

## តំណាងមហាអយ្យការ ស្នើសុំក្រុមប្រឹក្សាជំនុំជម្រះសម្រេច៖

-បដិសេធបណ្តឹងសាទុក្ខលេខ ៣៤ ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០២១ របស់លោក [redacted]ស៊ីវិន ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted]សាវេត ចោលជាអសាបង់។

+ជនជាប់ចោទឈ្មោះ [redacted]សាវេត បានឆ្លើយថា៖ នៅតុលាការថ្នាក់ក្រោមខ្លួនមិនបានឆ្លើយអីទាំងអស់ ខ្លួនពុំបានដឹងអ្វីទាំងអស់។

+លោក [redacted] បូរ៉ា ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទធ្វើសេចក្តីសន្និដ្ឋានថា៖ តាមបណ្តឹងឧទ្ធរណ៍កូនក្តីខ្លួនឈ្មោះ[redacted]សាវេត ស្នើសុំឱ្យមានការបន្ធូរបន្ថយទោស ។ ចំពោះសាលដីកាសាលាឧទ្ធរណ៍បានសម្រេចតម្កល់សាលក្រមសាលាដំបូងខេត្តព្រះវិហារ ដោយសម្រេចផ្តន្ទាទោសកូនក្តីខ្លួនចំនួន ០៥ឆ្នាំ និងឯកភាពតាមសំអាងហេតុរបស់សាលាដំបូងខេត្តព្រះវិហារ ។ កូនក្តីខ្លួនសំណូមពរសុំបាននៅក្រៅឃុំ ដើម្បីចិញ្ចឹមកូន ដោយសារគាត់មានកូនពីរនាក់ ពេលគាត់ជាប់ពន្ធនាគារ គាត់ពុំបានដឹងទេថា កូនគាត់នៅឯណា និងរស់នៅជាមួយអ្នកណា។ តាមមាត្រា ៩៣ នៃក្រមព្រហ្មទណ្ឌ បានចែងពីស្ថានសម្រាលទោស ដោយផ្អែកតាមភាពធ្ងន់ធ្ងរនៃបទល្មើស ដោយសារកូនក្តីខ្លួនមានជីវភាពក្រីក្រ ហើយប្តីរបស់គាត់មានការរឹងរូស បានទៅធ្វើអំពើនេះម្តងទៀត



Scanned with CamScanner

ជាហេតុនាំឱ្យមានការចាប់ខ្លួនដល់កូនក្តីខ្លួនឈ្មោះ [redacted] សារេត ហើយប្តីរបស់គាត់ បានរត់គេចខ្លួនបាត់។ ហើយការកាប់ទន្ទ្រានដីនេះ គឺមិនមែនមានតែកូនក្តីខ្លួនទេ គឺមានប្រជាពលរដ្ឋច្រើនណាស់ ។

សំណូមពរ សូមក្រុមប្រឹក្សាជំនុំជម្រះមេត្តាពិចារណា សម្រេចបន្ធូរបន្ថយទោសតាមរយៈការព្យួរទោសដល់កូនក្តីខ្លួន ដើម្បីឱ្យគាត់មានសេរីភាព។

+លោក [redacted]ស៊ីវិន ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទធ្វើសេចក្តីសន្និដ្ឋានថា៖ កូនក្តីខ្លួនបានប្រើពូថៅ រណា ដោយដៃតែប៉ុណ្ណោះ ហើយការកាប់ទន្ទ្រានដីនេះទើបតែបាន៥,៥ (ប្រាំហិកតាកន្លះ) ទេ ថ្ងៃដែលគេចាប់ខ្លួនកូនក្តីខ្លួនកំពុងតែដាំស្លនៅក្នុងខ្ទម លោកអនុប្រធានបរិស្ថាន [redacted] ញឹម បានប្តឹងកូនក្តីខ្លួនរឿងដីទំហំ ៥៣,៥ (ហាសិបបីហិកតាកន្លះ) តែជាក់ស្តែងកូនក្តីខ្លួនបានកាប់គាស់ដីបានទំហំ៥,៥ (ប្រាំហិកតាកន្លះ) ទេ ។ តុលាការបានបំបែកសំណុំរឿងជាពីរ កូនក្តីខ្លួនមានសំណុំរឿង០២ ហើយរឿង១ទៀតតុលាការបានសម្រេចឱ្យគាត់រួចខ្លួនហើយ នៅតែរឿងមួយនេះបានដាក់ទណ្ឌកម្ម ០៥ (ប្រាំ)ឆ្នាំ ។

សំណូមពរ សុំឯកឧត្តមប្រធានក្រុមប្រឹក្សា មេត្តាពិចារណាសម្រេច បង្វិលសំណុំរឿងនេះទៅសាលាឧទ្ធរណ៍ ។

-ក្រោយពីបានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

-ក្រោយពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទ និងសេចក្តីសន្និដ្ឋានរបស់មេធាវីការពារឱ្យជនជាប់ចោទ

-ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

## តុលាការកំពូល

១-យល់ឃើញថា បណ្តឹងសាទុក្ខលេខ ៣៤ ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០២១ របស់លោក [redacted]ស៊ីវិន ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] សារេត ធ្វើឡើងក្នុងកំណត់ច្បាប់តុលាការកំពូលអាចលើករឿងនេះមកជំនុំជម្រះបានតាមមាត្រា ៦៤ នៃច្បាប់ស្តីពីការរៀបចំអង្គការតុលាការ និងមាត្រា ៤២០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

២-យល់ឃើញថា នៅថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០២១ សាលាឧទ្ធរណ៍ត្បូងឃ្មុំ បានប្រកាសសេចក្តីសម្រេចនៃសាលដីកាព្រហ្មទណ្ឌលេខ ៩៤ ព្រទ.ក្រIII (ទ.ណ) ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០២១ របស់ខ្លួននៅចំពោះមុខជនជាប់ចោទឈ្មោះ [redacted] សារេត ហើយមិនសុខចិត្ត នឹងសេចក្តីសម្រេចនេះ ជនជាប់ចោទឈ្មោះ [redacted] សារេត បានយល់ព្រមឱ្យលោកមេធាវី [redacted] ស៊ីវិន ប្តឹងសាទុក្ខតាមបណ្តឹងលេខ ៣៤ ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០២១ ត្រង់ចំណុចនៃសេចក្តីសម្រេចទាំងមូល។ ពាក់ព័ន្ធនឹងបណ្តឹងសាទុក្ខរបស់លោកមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ តុលាការកំពូល ពិនិត្យឃើញថាបណ្តឹងសាទុក្ខនេះ ធ្វើឡើងហួសកំណត់ច្បាប់ ដែលមានចែងក្នុង កថាខណ្ឌទី១ មាត្រា ៤២០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។ ដូច្នេះបណ្តឹងសាទុក្ខខាងលើនេះ តុលាការកំពូលពុំអាចពិចារណាបាន ទេ។

៣-យល់ឃើញថា សាលដីកាព្រហ្មទណ្ឌលេខ ៩៤ ព្រទ.ក្រIII (ទ.ណ) ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០២១ របស់សភាព្រហ្មទណ្ឌសាលាឧទ្ធរណ៍ត្បូងឃ្មុំ ដែលបានសម្រេចសេចក្តីមកនេះ ត្រឹមត្រូវតាមផ្លូវច្បាប់។



Scanned with CamScanner

## ហេតុដូច្នេះ
## វិនិច្ឆ័យសេចក្ដី

១-បដិសេធបណ្ដឹងសាទុក្ខលេខ ៣៤ ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០២១ របស់លោក [redacted]ស៊ីវិន ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted]សារេត ។

២-តម្កល់សាលដីកាព្រហ្មទណ្ឌលេខ ៩៤ ព្រទ.ក្រIII (ទ.ណ) ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០២១ របស់សភាព្រហ្មទណ្ឌសាលាឧទ្ធរណ៍ត្បូងឃ្មុំ ទុកជាបានការពេញទាំងមូល ។

សាលដីកានេះ ជំនុំជម្រះជាសាធារណៈនៅថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០២១ និងប្រកាសជាសាធារណៈ នៅថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០២១ ។

| | | |
|---|---|---|
| ឯកឧត្ដម | [redacted] | ប្រធាន |
| ឯកឧត្ដម | [redacted] | ចៅក្រម |
| ឯកឧត្ដម | [redacted] | ចៅក្រម |
| ឯកឧត្ដម | [redacted] | ចៅក្រម |
| ឯកឧត្ដម | [redacted] | ចៅក្រម |
| លោកស្រី | [redacted] | ក្រឡាបញ្ជី |

---

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម ។
ថ្ងៃពុធ ១០រោច ខែមិគសិរ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
រាជធានីភ្នំពេញ ថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០២១
**ក្រឡាបញ្ជី**

[redacted]

**បានឃើញ**
ថ្ងៃពុធ ១០រោច ខែមិគសិរ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
រាជធានីភ្នំពេញ ថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០២១
**ប្រធានក្រុមប្រឹក្សាជំនុំជម្រះ**

[redacted]



Scanned with CamScanner